# ទីតាំងសម្អាតរបស់ Mt Baker Properties



ទីតាំងសម្អាតរបស់ *Mt Baker*

## ទំនាក់ទំនង និងព័ត៌មាន

**ទទួលយកមតិយោបល់៖**
ថ្ងៃទី28 ខែតុលា – ថ្ងៃទី26 ខែវិច្ឆិកា ឆ្នាំ 2019

**ប្រគល់ជូនមតិយោបល់តាមអនឡាញតាមរយៈ៖**
http://bit.ly/MtBakerComments

**ឬ មតិយោបល់ និងសំណួរ៖**
Sandra Matthews អ្នកគ្រប់គ្រងទីតាំងកម្មវិធីសម្អាតជាតិពុល
3190 160th Avenue SE
Bellevue, WA 98008
អ៊ីម៉ែល៖ Sandra.Matthews@ecy.wa.gov
ទូរសព្ទ៖ 425-649-7206

**គេហទំព័រទីតាំង៖**
http://bit.ly/MtBakerProperties

**ទីតាំងត្រួតពិនិត្យឯកសារ៖**
Beacon Hill Public Library
2821 Beacon Ave South
Seattle, WA 98144
ទូរសព្ទ៖ 206-684-4711

Ecology NW Regional Office
3190 160th Avenue SE
Bellevue, WA 98008
ទូរសព្ទសម្រាប់ការណាត់ជួប៖
425-649-7190

**អត្តសញ្ញាណទីតាំងអគារ៖**
96127971, 42746846

**អត្តសញ្ញាណការសម្អាតទីតាំង៖** 13054

## ផែនការសម្អាតដែលមានសម្រាប់ការត្រួតពិនិត្យឡើងវិញ

សមាគមលំនៅដ្ឋាន Mt. Baker Housing Association (MBHA) កំពុងសម្អាតទីតាំងសម្អាតរបស់ Mt Baker Properties (ហៅកាត់ថា "ទីតាំង") នៅក្នុងទីក្រុង ដោយមានការឃ្លាំមើលពីក្រសួងអេកូឡូស៊ី (ហៅកាត់ថា "អេកូឡូស៊ី")។ ឯកសារមួយចំនួនបានតាក់តែងឡើងសម្រាប់ជាផ្នែកមួយនៃកិច្ចដំណើរការនេះ ហើយនៅពេលនេះកំពុងត្រូវបានប្រគល់ជូនសាធារណៈជនដើម្បីផ្តល់មតិយោបល់។

ក្រសួងអេកូឡូស៊ី សូមអញ្ជើញអ្នកឲ្យចូលរួមពិនិត្យមើលឡើងវិញ និងផ្តល់មតិយោបល់ទៅលើឯកសារដូចខាងក្រោម៖3

- **Prospective Purchaser Consent Decree (PPCD, វិសោធនកម្មលើកិច្ចព្រមព្រៀងរបស់អនាគតអ្នកទិញ)** – ណែនាំ MBHA ឲ្យអនុវត្តការសម្អាតនៅតាមទីតាំង។
- **Remedial Investigation/Feasibility Study Report (RI/FS, របាយការណ៍ស្តីពីការសិក្សាអង្កេតកែតម្រូវ/ការសិក្សាអំពីសមិទ្ធិលទ្ធភាព)** – ពិពណ៌នាអំពីការបំពុលនៅតាមទីតាំង និងវាយតម្លៃលើជម្រើសចំនួនប្រាំសម្រាប់ការសម្អាត។
- **Draft Cleanup Action Plan (DCAP, ពង្រាងផែនសកម្មភាពសម្អាត)** – ពិពណ៌នាអំពីវិធីសាស្ត្រសម្អាតដែលនិយមប្រើប្រាស់សម្រាប់ការបំពុល និងបញ្ជាក់អំពីស្តង់ដានិងលក្ខខណ្ឌតម្រូវនានាស្តីពីសម្អាតនៅតាមទីតាំង។
- **តារាងត្រួតពិនិត្យ State Environmental Policy Act (SEPA, សកម្មភាពគោលនយោបាយបរិស្ថានរបស់រដ្ឋ) និង Determination of Non-Significance (DNS, ការកំណត់អំពីភាពមិនចាំបាច់)** – ការវាយតម្លៃនិងការកំណត់របស់ក្រសួងអេកូឡូស៊ី ដែលសកម្មភាពសម្អាតបណ្តោះអាសន្ននេះ ទំនងជាមិនមានគ្រោះថ្នាក់ដល់បរិស្ថាននោះទេ។

## ការប្រជុំសាធារណៈ និងព្រឹត្តិការណ៍សាធារណៈ

ក្រសួងអេកូឡូស៊ី នឹងប្រារព្ធកិច្ចប្រជុំសាធារណៈ និងព្រឹត្តិការណ៍សាធារណៈណាមួយដើម្បីផ្តល់ព័តមានបន្ថែមអំពីទីតាំង និងទទួលយកមតិយោបល់នានា។

**ថ្ងៃពុធ ទី6 ខែវិច្ឆិកា ឆ្នាំ2019 វេលាម៉ោង 6 – 8 យប់**
**បន្ទប់ប្រជុំ Mt Baker Village**
**2580 29th Avenue South**
**Seattle, WA 98144**

*សេវាបកប្រែឯកសារ/បកប្រែផ្ទាល់មាត់ នឹងមានផ្តល់ជូនជាភាសាអេស្ប៉ាញ ចិន វៀតណាម និងខ្មែរ។*

## សារតារទីតាំង

ទីតាំងនេះ ស្ថិតនៅចំណុចប្រសព្វនៃផ្លូវ South McClellan និងផ្លូវ MLK Way South នៅក្នុងទីក្រុង Seattle ។ វាផ្សំឡើងដោយទីតាំងអចលនទ្រព្យចំនួនប្រាំកន្លែង។ ទីតាំងអចលនទ្រព្យចំនួនបួនកន្លែង ស្ថិតនៅអាសយដ្ឋានលេខ 2802, 2806, 2810, និង 2864 វិថី South McClellan Street ត្រូវបានហៅជារួមថា “ដីឡូត៍ McClellan Parcels”។ ទីតាំងអចលនទ្រព្យទីប្រាំ គឺជាអតីតស្ថានីយប្រេងឥន្ធនៈមួយកន្លែងដែលមានទីតាំងស្ថិតនៅផ្លូវ 2800 MLK Way South, នៅខាងកើតភាគខាងត្បូងនៃចំណុចប្រសព្វ និងត្រូវបានគេស្គាល់ថាជា "អតីតដីឡូត៍ស្ថានីយប្រេងឥន្ធនៈ" (សូមមើលផែនទីនៅទំព័រ 5)។

អតីតស្ថានីយប្រេងឥន្ធនៈ ក៏ធ្លាប់ជាកន្លែងអាជីវកម្មថែទាំនិងជួសជុលរថយន្តផងដែរ ដែលបានដំណើរការចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1950 រហូតដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ 2000 ។ វាមានគ្មានមនុស្សស្នាក់នៅទេ ប៉ុន្តែមានអគារនៅទីនោះ។ អតីតហាងបោកគក់មួយកន្លែង មានទីតាំងស្ថិតនៅវិថី 2864 South McClellan ។ វាបានដំណើរការចាប់តាំងពីឆ្នាំ 1940 រហូតដល់ចុងឆ្នាំ 2018 និងជាប្រភពនៃការបំពុលពាក់ព័ន្ធនឹងការបោកគក់នៅក្រោមក្បាលដី McClellan និងទីតាំងអចលនទ្រព្យនិងផ្លូវសម្រាប់ធ្វើដំណើរឆ្លងកាត់ផ្សេងទៀតនៅជុំវិញនោះ។




អតីតហាងជួសជុលរថយន្ត និងស្ថានីយប្រេងឥន្ធនៈ

នៅក្នុងឆ្នាំ 2016, ក្រសួងអេកូឡូស៊ី និង MBHA បានចុះកិច្ចព្រមព្រៀងផ្លូវច្បាប់មួយដែលមានឈ្មោះថា **Prospective Purchaser Consent Decree (PPCD)** ដើម្បីធ្វើការអង្កេត និងសម្អាតទីតាំងនេះ។ MBHA កំពុងដំណើរការការសម្អាតទីតាំងចំនួនប្រាំកន្លែង ដើម្បីឲ្យខ្លួនអាចអភិវឌ្ឍទីតាំងទាំងនេះទៅជាលំនៅដ្ឋានដែលមានតម្លៃថោកសមរម្យនៅក្នុងទីក្រុង Seattle។ ការសិក្សាអង្កេតលើបរិស្ថាន ត្រូវបានចប់សព្វគ្រប់ ហើយវិធីសាស្ត្រសម្អាតទីតាំងនេះត្រូវបានធ្វើការវាយតម្លៃ។




កន្លែងបោកគក់ *Mt Baker*

## ការសិក្សាអង្កេតលើទីតាំង និងការបំពុល

ការសិក្សាអង្កេតកែតម្រូវនៅតាមទីតាំងបានរកឃើញថាធាតុរំលាយ និងអ៊ីដ្រូកាបូននៃប្រេងសាំងបានមកពីកន្លែងបោកគក់ និងអតីតស្ថានីយប្រេងឥន្ធនៈ/ការដំណើរការជួលជុលរថយន្ត បានបំពុលទៅដល់ដី និងទឹកក្រោមដី។ សារធាតុពុលមួយចំនួន ក៏បញ្ចេញចំហាយបំភាយទៅក្នុងខ្យល់អាកាសផងដែរ។ សារធាតុពុលទាំងនេះ ត្រូវតែធ្វើការដោះស្រាយក្រោមច្បាប់ស្តីពីការសម្អាតរបស់រដ្ឋ Washington គឺច្បាប់ Model Toxics Control Act (MTCA, បទប្បញ្ញត្តិស្តីពីការគ្រប់គ្រងសារធាតុពុលគំរូ)។

## ជម្រើសនៃការសម្អាត

ការសិក្សាស្តីពីសមិទ្ធិលទ្ធភាពបានបង្កើតនូវជម្រើសចំនួនប្រាំ ដែលត្រូវបានវាយតម្លៃសម្រាប់ទីតាំងនេះ។ វាបានវាយតម្លៃទៅលើជម្រើសស្តីពីអចិន្ត្រៃយ៍ភាព ប្រសិទ្ធភាព លទ្ធភាពការពារ និងលទ្ធភាពនៃការអនុវត្ត ហានិភ័យរយៈពេលខ្លីនិងរយៈពេលវែង ក្តីកង្វល់ជាសាធារណៈ និងថ្លៃចំណាយ។ តាមរយៈនេះ ជម្រើសដែលនិយមប្រើប្រាស់ ត្រូវបានកំណត់ និងតាក់តែងឡើងទៅក្នុងផែនការសកម្មភាពសម្អាត (សូមមើលទំព័រទី 3)។

## ពង្រាងផែនការសកម្មភាពសម្អាត

DCAP ពិពណ៌នាអំពីជម្រើសសម្អាតជាទីពេញនិយម ដែលត្រូវបានកំណត់នៅក្នុង FS ថាជាសកម្មភាពសម្អាតដែលបានជ្រើសរើសសម្រាប់ទីតាំងនេះ។ ផែនការនេះរួមមានសកម្មភាពសម្អាតដូចខាងក្រោម៖

- ការជីកកាយដី៖ ជីកកាយដីដែលជាប្រភពសម្រាប់ការបំពុលទឹកក្រោមដី។
- ការគ្រប់គ្រងស្ថាប័ន៖ ប្រើប្រាស់ការគ្រប់គ្រងផ្នែករដ្ឋបាលឬផ្នែកវិស្វកម្ម ដើម្បីបង្ការការប្រឈមទៅនឹងជាតិពុលដូចជាការបិទគម្រប របាំងចំហាយបំភាយ ប្រព័ន្ធកាត់បន្ថយសម្ពាធក្រោមប្លង់សេ (sub-slab depressurization systems) និងការរឹតត្បិតលើប្លង់កម្មសិទ្ធិ។
- ការធ្វើរ៉េដុកម្មគីមីនៅនឹងកន្លែង៖ បាញ់បញ្ចូល ឬដាក់សារធាតុគីមី (ដូចជាធាតុដែកដែលមានវ៉ាឡង់សូន្យ) ទៅក្នុងទឹកក្រោមដីដែលធ្វើប្រព្រឹត្តិកម្មជាមួយសារធាតុពុលតាមរយៈរ៉េដុកម្មគីមី។
- ភាពកករឹងនៃដីនៅនឹងកន្លែង៖ កាត់បន្ថយលទ្ធភាពអាចជ្រាបចេញបាននៃដីដែលបានបំពុល ដោយការលាយចូលគ្នានៃដីនៅតាមទីតាំង និងការបន្ថែមប្រតិករដែលមានលក្ខណៈស្អិតជាប់ ដើម្បីធ្វើឲ្យដីកករឹង និងបង្ការការជ្រាបនៃសារធាតុពុលចូលទៅក្នុងទឹកក្រោមដី។
- ការកាត់បន្ថយតាមបែបធម្មជាតិដែលមានការគ្រប់គ្រង៖ ត្រួតពិនិត្យយ៉ាងសកម្មលើការកម្ចាត់សារធាតុពុលចេញពីទឹកក្រោមដីតាមរយៈប្រតិកម្មដែលកើតមានតាមធម្មជាតិដូចជាការរលាយបែបជីវសាស្ត្រ ការស្រូប ការពង្រាវ និងរបាយ។
- MBHA នឹងត្រួតពិនិត្យរាល់ការធ្វើប្រព្រឹត្តិកម្មទាំងអស់ក្រោយពេលសម្អាត ដើម្បីធានាថាពួកគេមានដំណើរការប្រព្រឹត្តទៅក្រោមការត្រួតពិនិត្យរបស់ក្រសួងអេកូឡូស៊ី។

## តារាងត្រួតពិនិត្យ SEPA និងការកំណត់អំពីភាពមិនចាំបាច់

SEPA តម្រូវឲ្យមានការពិចារណាទៅលើផលប៉ះពាល់ផ្នែកបរិស្ថាននៃគម្រោងនេះ។ ក្រសួងអេកូឡូស៊ី បានធ្វើការវាយតម្លៃលើការងារគម្រោងនិងការសម្អាត ដែលបានរៀបរាប់នៅក្នុង DCAP និងបានកំណត់ថាវាអាចនឹងមិនមានផលប៉ះពាល់អវិជ្ជមានគួរឲ្យកត់សម្គាល់ណាមួយទៅលើបរិស្ថាននោះទេ។

## តើមានអ្វីកើតឡើងនៅពេលបន្ទាប់?

ក្រោយរយៈពេលផ្ដល់មតិយោបល់រយៈពេល 30 ថ្ងៃមក ក្រសួងអេកូឡូស៊ីនឹងពិនិត្យមើល និងឆ្លើយតបទៅកាន់មតិយោបល់នានាដែលទទួលបានពីរយៈពេលផ្ដល់មតិយោបល់សាធារណៈនេះ។ ក្រសួងអេកូឡូស៊ី នឹងពិចារណារាល់មតិយោបល់ទាំងអស់ដែលទទួលបាន និងអាចកែតម្រូវឯកសារនានាដោយផ្អែកលើមតិយោបល់របស់អ្នក។ បន្ទាប់ពីនោះមក របាយការណ៍ RI/FS និង DCAP នឹងធ្វើការពិនិត្យសម្រេចចុងក្រោយ។ ទីតាំងនេះនឹងបន្តកិច្ចដំណើរការដើម្បីធ្វើការសម្អាត។

### *កិច្ចដំណើរការសម្អាតរបស់ក្រសួងអេកូឡូស៊ី*



## ផែនការសម្រាប់ការបំពុល និងការសម្អាតនៅទីតាំងសម្អាតរបស់ *Mt Baker Properties*



*ទីតាំងសម្អាតរបស់ **Mt Baker Properties** និងទីតាំងជុំវិញ*




**En Espanol**

El Departamento de Ecología esta anunciando el periodo de comentario público relacionado a la limpieza ambiental del sitio Mt Baker Properties Cleanup Site. Ecología también organizará una reunión pública para este sitio. Servicios de traducción e interpretación en español estarán disponibles. **La reunión será: miércoles 6 de noviembre de 2019; 6 – 8 PM, Sala de Reuniones de Mt. Baker Village, 2580 29th Avenue South, Seattle, WA 98144.** Para obtener este documento, o más información sobre este sitio en español, favor de comunicarse con Gretchen Newman al 360-407-6097 o preguntas@ecy.wa.gov

**Vietnamese**

Bo Mo i Sinh tho ng ba o đe n co ng chu ng ve khung thờ i gian go p y cho co ng ta c la m sa ch mo i trườ ng khu vư c Mt Baker Properties Cleanup Site. Bộ Môi Sinh - Ecology sẽ tổ chức buổi họp cộng đồng cho địa điểm này. Thông dịch viên tiếng Việt sẽ có mặt tại buổi họp: **Thứ Tư, ngày 6 tháng 11 năm 2019 - Từ 6pm-8pm, Phòng họp Mt Baker Village, 2580 29th Avenue South, Seattle, WA 98144**. Ne u quy vi muo n nha n ta i lie u na y ba ng tie ng Vie t hoa c ca n the m tho ng tin, xin lie n he o ng Lie m Nguye n 360-407-6955, đie n thư: Lngu461@ecy.wa.gov

**Chinese**

華盛頓州生態管理署邀請公眾對 Mt Baker 地產清理工作的清理行動計劃草案動提供建意見。 欲了解更多信息， 或要求翻譯服務，請致電林昊 (425) 649-7487，電子郵件 sunny.becker@ecy.wa.gov，**華盛頓州生態管理署將主辦一個公眾建議會議。會議中有中文翻譯服務。 會議將在：2019 年 11 月 6 日，星期三; 下午 6-8, Mt Baker Village Meeting Room, (貝克山村會議室), 2580 29th Avenue South, Seattle, WA 98144**

**Khmer**

ក្រសួងអេកូឡូស៊ី (Ecology) កំពុងប្រកាសអំពីរយៈពេលផ្តល់មតិយោបល់ជាសាធារណៈសម្រាប់ទីតាំងសម្អាតរបស់ Mt Baker Properties។ រយៈពេលផ្តល់មតិយោបល់នេះ នឹងចាប់ផ្តើមពីថ្ងៃទី28 ខែតុលា – ថ្ងៃទី26 ខែវិច្ឆិកា ឆ្នាំ2019។ ក្រសួងអេកូឡូស៊ី (Ecology) ក៏នឹងរៀបចំកិច្ចប្រជុំសាធារណៈមួយសម្រាប់ទីតាំងនោះផងដែរ។ សេវាបកប្រែឯកសារ និងសេវាបកប្រែផ្ទាល់មាត់ជាភាសាខ្មែរ នឹងមានផ្តល់ជូន។ កិច្ចប្រជុំនេះ នឹងប្រព្រឹត្តទៅនៅ៖
ថ្ងៃពុធ ទី6 ខែវិច្ឆិកា ឆ្នាំ2019 វេលាម៉ោង 6 - 8 យប់
បន្ទប់ប្រជុំ Mt Baker Village
2580 29th Avenue South, Seattle, WA 98144

**Toxics Cleanup Program**
3190 160th Ave SE
Bellevue, WA 98008

# ចូលរួមទៅក្នុងកិច្ចពិភាក្សាអំពីការសម្អាត!




## ទីតាំងសម្អាតរបស់ Mt Baker Properties

ក្រសួងអេកូឡូស៊ី កំពុងស្វែងរកការផ្តល់មតិយោបល់ជាសាធារណៈស្តីពីពង្រាងផែនការសម្អាត និងឯកសារពាក់ព័ន្ធសម្រាប់ទីតាំងសម្អាតរបស់ Mt Baker Properties ។ សូមមើលផ្នែកខាងក្នុងសម្រាប់ព័ត៍មានលម្អិត!

### រយៈពេលផ្តល់មតិយោបល់ជាសាធារណៈ

ថ្ងៃទី28 ខែតុលា – ថ្ងៃទី26 ខែវិច្ឆិកា ឆ្នាំ2019 ។

### ការប្រជុំជាសាធារណៈ

ថ្ងៃពុធ ទី6 ខែវិច្ឆិកា ឆ្នាំ2019
បន្ទប់ប្រជុំ Mt Baker Village
2580 29th Avenue South
Seattle, WA 98144

**សំណើសុំការសម្របសម្រួល៖** ដើម្បីស្នើសុំការសម្របសម្រួល រួមទាំងឯកសារជាទម្រង់ណាមួយសម្រាប់អ្នកដែលមានកម្សោយចក្ខុ សូមទូរសព្ទទៅក្រសួង អេកូឡូស៊ីតាមរយៈលេខ 360-407-7668 ឬចូលទៅកាន់ https://ecology.wa.gov/accessibility ។ អ្នកដែលមានកម្សោយផ្នែកស្តាប់អាចទូរសព្ទទៅសេវាបញ្ជូនបន្តរបស់រដ្ឋ Washington តាមរយៈលេខ 711 ។ អ្នកដែលមានពិការភាពផែកភាសានិយាយ អាចហៅទៅខ្សែទូរសព TTY តាមរយៈលេខ 877-833-6341 ។